**LOWELL PUBLIC SCHOOLS**
ការិយាល័យរដ្ឋបាលកណ្តាល Henry J. Mroz
155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2020

ជូនចំពោះក្រុមគ្រួសារសង្កាត់សាលា Lowell Public Schools ទាំងអស់៖

ខ្ញុំសង្ឃឹមថា លិខិតនេះនឹងទៅដល់អ្នកទាំងអស់គ្នា ទាំងលោកអ្នកមានសុវត្ថិភាព និង សុខភាពល្អនៅអំឡុងពេលដ៏លំបាកទាំងនេះ។ ចាប់តាំងពីថ្ងៃទី 19 ខែ តុលា មក 97% នៃសិស្សទាំងអស់របស់យើងបាននិងកំពុងចូលរួមក្នុងការរៀនសូត្រពីចម្ងាយ ដោយសារអត្រាកំពុងកើនឡើងនៃជំងឺ COVID-19 នៅទីនេះក្នុងក្រុង Lowell ។ នៅខណៈពេលនេះដែរ ចំនួនភាគរយតិចតួចនៃសិស្សនៅក្នុងថ្នាក់អប់រំពិសេសដាច់ដោយឡែកបានបន្តមានជម្រើសដើម្បីចូលរួមនៅក្នុងការបង្ហាត់បង្រៀននៅក្នុងបរិវេណសាលា និង ដោយផ្ទាល់ ចាប់តាំងពីថ្ងៃដំបូងនៃការចូលរៀន។ តាមរយៈវិបត្តិសុខភាពមិនធ្លាប់មានពីមុនមកនេះ យើងបានផ្តល់អាទិភាពដល់ការមានសិស្សងាយរងគ្រោះបំផុតរបស់យើងដែលត្រូវសិក្សានៅបរិវេណសាលា ដោយសារតែសេចក្តីត្រូវការខ្លាំងតាមជំនាញរបស់ពួកគេ និង កម្រិតពាក់ព័ន្ធនៃសេវាកម្ម និង ការបង្ហាត់បង្រៀនដែលពួកគេទទួលបានជារៀងរាល់ថ្ងៃ។

យើងនៅតែមានទំនុកចិត្តលើកម្រិតសុវត្ថិភាពនេះនៅក្នុងអគារសិក្សារបស់យើង ដោយសារមានពិធីសារតឹងរ៉ឹង ប៉ុន្តែការរីករាលដាលទូទាំងសហគមន៍នៃជំងឺ COVID-19 ដែលបានកើនឡើងដល់ទៅជាង 100 ករណីក្នុងអ្នកស្រុកក្រុង Lowell ចំនួន 100,000 នាក់កាលពីសប្តាហ៍មុននេះ នឹងត្រូវបន្តមានផលប៉ះពាល់កាន់តែខ្លាំងក្លាបន្ថែមទៀតទៅលើវត្តមានបុគ្គលិក និង អ្នកជំនួស ដោយសារការប៉ះពាល់ និង ការធ្វើចត្តាឡីស័កពីជំងឺនេះ។ នៅក្នុងកម្រិតល្បឿនបច្ចុប្បន្ន អាត្រានៃការឆ្លងទូទាំងសហគមន៍នៃជំងឺ COVID-19 នឹងធ្វើឲ្យប៉ះពាល់ដល់និរន្តភាពនៃការធ្វើកម្មវិធីដោយផ្ទាល់របស់យើងនៅប៉ុន្មានថ្ងៃខាងមុខដោយមិនអាចជៀសផុតឡើយ ដោយសារយើងត្រូវបង្ខំចិត្តធ្វើចត្តាឡីស័កលើសាលា និង បន្ទប់រៀននីមួយៗ។ ហេតុនេះហើយ ដើម្បីផ្តល់ជូនក្រុមគ្រួសារនូវការជូនដំណឹងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន និង ដើម្បីបំបាត់ចោលកម្មវិធីដែលអាចធ្វើឡើងនៅវេនយប់ ទៅកាន់ការរៀនសូត្រពីចម្ងាយ (ដែលអាចធ្វើឡើងតាមការចាំបាច់តាមពិធីសារចត្តាឡីស័ករបស់យើង) **គ្រប់កម្មវិធីអប់រំពិសេសដាច់ដោយឡែកទាំងអស់ដែលបច្ចុប្បន្ននេះធ្វើឡើងនៅក្នុងបរិវេណសាលា នឹងត្រូវផ្លាស់ទៅកាន់ការរៀនសូត្រពីចម្ងាយ នៅអំឡុងពេលមួយសប្តាហ៍មិនពេញលេញមុនពេលដល់វិស្សមកាលរដូវរងារដែលរួមមាន៖**

**ថ្ងៃ ចន្ទ ទី 21 ខែ ធ្នូ**
**ថ្ងៃ អង្គារ ទី 22 ខែ ធ្នូ**
**ថ្ងៃ ពុធ ទី 23 ខែ ធ្នូ**

សិស្សទាំងនេះនឹងបន្តចូលរៀននៅសាលាដោយផ្ទាល់សម្រាប់សប្តាហ៍ខាងមុខគឺពីថ្ងៃទី 14-18 ខែ ធ្នូ ហើយយើងមានគម្រោងឲ្យសិស្សទាំងនេះត្រលប់មកកាន់ការបង្ហាត់បង្រៀនដោយផ្ទាល់វិញឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីវិស្សមកាលរដូវរងារបានបញ្ចប់ ដោយថ្ងៃដំបូងនៃការត្រលប់ទៅសាលារៀនវិញនៅបច្ចុប្បន្ននេះត្រូវបានគ្រោងធ្វើឡើងនៅថ្ងៃ ចន្ទ ទី 4 ខែ មករា។

យើងយល់ពីផលប៉ះពាល់ដែលការសម្រេចចិត្តទាំងនេះមានទៅលើសិស្សនិងក្រុមគ្រួសារ ដូច្នេះហើយ លិខិតនេះគឺមានបំណងដើម្បីផ្តល់ជូននូវការជូនដំណឹងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីអាចឲ្យគ្រួសាររៀបចំផែនការសម្រាប់ថ្ងៃរៀនសូត្រពីចម្ងាយរយៈពេលបី (3) ថ្ងៃទាំងនេះ ដូចមានរាយនៅខាងលើ។

ចំណែកការក្រើនរំលឹកដល់សិស្សដែលចូលរៀនពីចម្ងាយ យើងនឹងបន្តជាមួយនឹងផែនការរៀនសូត្រពីចម្ងាយបច្ចុប្បន្នរបស់យើង រហូតដល់មានការជូនដំណឹងបន្ថែមទៀត។ យើងមានគម្រោងផ្តល់ជូននូវបច្ចុប្បន្នភាពមួយដល់ក្រុមគ្រួសារ នៅមុនពេលវិស្សមកាលរដូវរងារនេះ។

សូមអរគុណម្តងទៀតសម្រាប់ការបន្តជាដៃគូនិងការបត់បែនតាមកាលៈទេសៈរបស់លោកអ្នក ខណៈពេលដែលយើងប្រឹងប្រែងរក្សាសុវត្ថិភាពដល់សិស្ស ក្រុមគ្រួសារ និង បុគ្គលិករបស់យើង នៅអំឡុងពេលដ៏លំបាកនិងមិនប្រាកដប្រជាទាំងនេះ។

ដោយក្តីស្មោះស្ម័គ្រពី

Joel Boyd

បណ្ឌិត Joel D. Boyd
អ្នកគ្រប់គ្រងសង្កាត់សាលា